ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ១០/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៨ និងពិធីចុះហត្ថលេខាលើលិខិតូបករណ៍ចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៨ ដឹកនាំដោយ ឯកឧត្តម ដាតុ ស៊េរី យូតាមា ហាជី មហាម៉ាដ ប៊ីន ហាជី ហាហ្សាន រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី និងពិធីចុះហត្ថលេខាលើលិខិតូបករណ៍ចូលជាភាគីនៃសន្ធិសញ្ញាស្តីពីមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ដោយអាល់ហ្សេរី និងអ៊ុយរូហ្គាយ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥។

## កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៨

រដ្ឋមន្ត្រីការបរទេសបានពិភាក្សាអំពីកិច្ចខិតខំកសាងសហគមន៍អាស៊ាន និងវឌ្ឍនភាពក្នុងការសម្រេចបាននូវអាទិភាព និងលទ្ធផលសំខាន់ៗរបស់អាស៊ានសម្រាប់ឆ្នាំ២០២៥ ក្រោមមូលបទ "បរិយាបន្ន និងចីរភាព"។ កិច្ចប្រជុំក៏បានកត់សម្គាល់ផងដែរ អំពីរបាយការណ៍សង្ខេបដោយក្រុមការងារភូមិសាស្ត្រសេដ្ឋកិច្ចអាស៊ាន (AGTF) ដែលបានគូសបញ្ជាក់ពីតម្រូវការជាបន្ទាន់សម្រាប់អាស៊ាន ក្នុងការឆ្លើយតបជាយុទ្ធសាស្ត្រចំពោះទិដ្ឋភាពភូមិសាស្ត្រសេដ្ឋកិច្ចសកលដ៏ស្មុគស្មាញ។ ក្នុងន័យនេះ កិច្ចប្រជុំបានចូលរួមក្នុងការអំពាវនាវឱ្យពង្រឹងភាពធន់ក្នុងតំបន់ តាមរយៈការលើកកម្ពស់ពាណិជ្ជកម្មក្នុងអាស៊ាន ការសម្របសម្រួលអន្តរសសរស្តម្ភក្នុងការរៀបចំគោលនយោបាយ ការចូលរួមពីវិស័យឯកជន និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (FTAs) ជាពិសេសភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP)។

កិច្ចប្រជុំក៏បានស្វាគមន៍ផងដែរ ចំពោះចំណាប់អារម្មណ៍កាន់តែច្រើនឡើងក្នុងការចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ដែលបញ្ជាក់សារជាថ្មីអំពី


អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

សារៈសំខាន់នៃសន្ធិសញ្ញា TAC ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ហើយទន្ទឹងរង់ចាំការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៥០ របស់សន្ធិសញ្ញា TAC នៅឆ្នាំ ២០២៦ ក្រោមភាពជាប្រធានអាស៊ានរបស់ហ្វីលីពីន។ ជាមួយនឹងការអនុម័តនូវគោលការណ៍ណែនាំ ដើម្បីសម្រួលដល់ការចូលជាសមាជិករបស់ទីម័រឡេស្តេក្នុងលិខិតូបករណ៍គតិយុត្តអាស៊ាន កិច្ចប្រជុំបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការគាំទ្រទីម័រឡេស្តេ ចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ នៅខែតុលា ក្នុងឆ្នាំនេះ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការប្រើយន្តការដឹកនាំដោយអាស៊ានឱ្យអស់លទ្ធភាពដើម្បីជាវេទិកាគន្លឹះសម្រាប់ការកសាងទំនុកចិត្ត និងការចូលរួមក្នុងន័យស្ថាបនាជាមួយដៃគូខាងក្រៅ និងភាពបន្ទាន់ក្នុងការជំរុញពាណិជ្ជកម្មក្នុងអាស៊ាន និងសមាហរណកម្មក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ ជាពិសេសតាមរយៈការទាញយកកាលានុវត្តភាពពីវិស័យដែលកំពុងលេចឡើងថ្មីៗ ដូចជា វិស័យឌីជីថលនិងសេដ្ឋកិច្ចបៃតង ខ្សែច្រវាក់ផ្គត់ផ្គង់ និងនវានុវត្តន៍។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការជួយសម្រួលដល់ទីម័រឡេស្តេចូលជាសមាជិកពេញសិទ្ធរបស់អាស៊ាន តាមរយៈការកសាងសមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីឱ្យទីម័រឡេស្តេមានលទ្ធភាពរួមចំណែកយ៉ាងសកម្មក្នុងនាមជាសមាជិកទី១១ របស់អាស៊ាន។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ចប់ដោយរំលឹកឡើងវិញ ពីការគាំទ្ររបស់កម្ពុជាចំពោះតួកគីយ៉េក្នុងការក្លាយជាដៃគូសន្ទនាអាស៊ាន ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការពង្រឹងទំនាក់ទំនងខាងក្រៅរបស់អាស៊ាន និងការចូលរួមជាសកលក្នុងការលើកស្ទួយសន្តិភាព ស្ថិរភាព និងវិបុលភាពតំបន់។

នៅក្នុងសម័យប្រជុំចង្អៀត កិច្ចប្រជុំបានពិភាក្សាពីការតាមដានការវាយតម្លៃ និងសេចក្តីសម្រេចចិត្តរបស់ប្រមុខដឹកនាំអាស៊ាន ស្តីពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច (5PC)។ កិច្ចប្រជុំបានបញ្ជាក់សាជាថ្មីពីសារៈសំខាន់នៃមជ្ឈភាព និងសាមគ្គីភាពអាស៊ាន ក្នុងការពង្រឹងការឆ្លើយតបរួមរបស់អាស៊ានចំពោះបញ្ហាប្រឈមក្នុងតំបន់ និងពិភពលោក រួមទាំងតាមរយៈការពង្រឹងការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ។

**<u>ពិធីចុះហត្ថលេខាលើលិខិតូបករណ៍ចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC)</u>**

ក្នុងឱកាសកិច្ចប្រជុំខាងលើ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងរដ្ឋមន្ត្រីការបរទេសអាស៊ានផ្សេងទៀត បានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើលិខិតូបករណ៍ចូលជាភាគីនៃសន្ធិសញ្ញា TAC ដោយអាល់ហ្សេរី និងអ៊ុយរូហ្គាយ។ **ឯកឧត្តម** Ahmed ATTAF រដ្ឋមន្ត្រីការបរទេសអាល់ហ្សេរី និង **ឯកឧត្តម** Mario LUBETKIN រដ្ឋមន្ត្រីការបរទេសអ៊ុយរូហ្គាយ បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះគុណតម្លៃនិងគោលការណ៍របស់អាស៊ាន ចំពោះសន្តិសហវិជ្ជមាន ការគោរពគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការមិត្តភាពនៅតំបន់អាស៊ីអាគ្នេយ៍។

**កិច្ចប្រជុំទ្វេភាគី ក្នុងឱកាសកិច្ចប្រជុំខាងលើ**

មុនពេលចូលរួមកិច្ចប្រជុំអាស៊ាននានាខាងលើ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលរួមអាហារការងារពេលព្រឹកជាមួយ**ឯកឧត្តម** Thongsavanh PHOMVIHANE រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង **ឯកឧត្តម** BUI Thanh Son ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិភាក្សាគ្នាលើការធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបី៕

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥